បញ្ជីហេតុការណ៍សម្រាប់អ្នកទទួលនិងអ្នកថែរទាំ
ការអនុញ្ញាតឲ្យប្រើប្រាស់ជាបន្ទាន់(EUA) នៃវ៉ាក់សាំងម៉ូឌែណាកូវីដ19
(MODERNA COVID-19)ដើម្បីបង្ការជម្ងឺកូរ៉ូណា2019(COVID-19)
សម្រាប់បុគ្គលម្នាក់ៗដែលមានអាយុចាប់ពី18 ឆ្នាំឡើងទៅ

អ្នកនឹងត្រូវបានផ្តល់វ៉ាក់សាំង Moderna COVID-19ដើម្បីបង្ការជម្ងឺកូរ៉ូណា2019(COVID-19)
ដែលបង្ករដោយវីរុសសារកូវីពីរ(SARS-CoV-2) ។

បញ្ជីហេតុការណ៍នេះមានផ្តុកព័ត៌មានដើម្បីជួយអ្នកយល់ដឹងពីហានិភ័យ និងអត្ថប្រយោជន៍នៃវ៉ាក់សាំង Moderna COVID-19 ដែលអ្នកអាចនឹងទទួលបានដោយសារវាមានការរាលដាលទៅគ្រប់កន្លែងនៃជម្ងឺ COVID-19 ក្នុងពេលបច្ចុប្បន្ននេះ។

វ៉ាក់សាំង MODERNA COVID-19 គឺជាវ៉ាក់សាំងមួយប្រភេទ ហើយអាចនឹងបង្ការអ្នកមិនឲ្យកើត ជម្ងឺ COVID-19 ។

សូមអានន្ទរបញ្ជីហេតុការណ៍នេះសម្រាប់ព័ត៌មានស្តីអំពីវ៉ាក់សាំង Moderna COVID-19 ។
សូមពិភាក្សាជាមួយអ្នកផ្តល់ការចាក់វ៉ាក់សាំងបង្ការរោគ ប្រសិនបើអ្នកមានសំណួរទាំងឡាយ។
វាគឺជាជម្រើសរបស់អ្នកក្នុងការជ្រើសរើសយកវ៉ាក់សាំង Moderna COVID-19 ។

វ៉ាក់សាំង Moderna COVID-19 បានទទួលការអនុញ្ញាតឲ្យប្រើប្រាស់ជាបន្ទាន់(EUA)
ពីរដ្ឋបាលចំណីអាហារសហរដ្ឋអាមេរិក(FDA)ដើម្បីផ្តល់៖

- សេរីពីរដូសលើកទីមួយសម្រាប់បុគ្គលដែលមានអាយុពី18 ឆ្នាំឡើងទៅ ។
- កម្រិតថ្នាំជាសេរីលើកទី 3 ដល់បុគ្គលដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ
  ដែលត្រូវបានកំណត់ថាមានប្រភេទមួយចំនួននៃការបាត់បង់ភាពស៊ាំទៅនឹងជម្ងឺ(
  immunocompromise) ។
- ចាក់ថ្នាំបង្ការរោគបន្ថែមតែមួយដងដល់បុគ្គលដែលមានអាយុចាប់ពី18
  ឆ្នាំឡើងទៅដែលបានបញ្ចប់សេរីលើកទីមួយជាមួយវ៉ាក់សាំង Moderna COVID-19នេះ។

- ចាក់ថ្នាំបង្ការរោគបន្ថែមតែមួយដងដល់បុគ្គលដែលមានអាយុចាប់ពី18 ឆ្នាំឡើងទៅ
  ដែលបានបញ្ចប់ការចាក់វ៉ាក់សាំងលើកទីមួយជាមួយនឹងវ៉ាក់សាំង COVID-19
  ដែលទទួលបានការអនុញ្ញាតឬអនុម័តុផ្សេងគ្នា។

វ៉ាក់សាំង Moderna COVID-19 អាចនឹងមិនការពារមនុស្សគ្រប់រូបនោះទេ។

បញ្ជីហេតុការណ៍នេះអាចត្រូវបានគេធ្វើបច្ចុប្បន្ន។ សម្រាប់ព័ត៌មានថ្មីៗបំផុតនៃបញ្ជីហេតុការណ៍
សូមចូលទៅទស្សនាគេហទំព័រ www.modernatx.com/covid19vaccine-eua ។

តើអ្វីខ្លះដែលអ្នកត្រូវដឹងមុននឹងអ្នកទទួលវ៉ាក់សាំងនេះ?

តើ COVID-19 ជាអ្វី?

COVID-19 គឺជាជម្ងឺដែលបង្ករឡើងដោយវីរុសកូរ៉ូណាដែលគេហៅថា SARS-CoV-2 ។
វីរុសកូរ៉ូណាប្រភេទនេះមិនត្រូវបានគេស្គាប់ឃើញមានពីមុនមកនោះទេ។ អ្នកអាចទទួល COVID-19
តាមរយៈការប៉ះពាល់ជាមួយមនុស្សដទៃទៀតដែលមានវីរុសនេះ។
ភាគច្រើនបំផុតគឺជម្ងឺផ្លូវដង្ហើមដែលអាចប៉ះពាល់ដល់សរីរាង្គដទៃទៀត។ មនុស្សដែលមាន COVID-19
មានរោគសញ្ញាជាច្រើនដែលត្រូវបានគេរាយការណ៍ ផ្តើមចេញពីរោគសញ្ញាល្មមៗទៅជម្ងឺធ្ងន់ធ្ងរ។
រោគសញ្ញាទាំងឡាយអាចលេចឡើងក្នុងរយៈពេលពី 2 ទៅ 14ថ្ងៃក្រោយពីការប៉ះពាល់វីរុស។
រោគសញ្ញាទាំងឡាយរួមមាន ក្តៅខ្លួនឬក្រុនញាក់ ក្អក ពិបាកដកដង្ហើម អស់កម្លាំង ឈឺសាច់ដុំឬឈឺខ្លួន ឈឺក្បាល
បាត់បង់រស់ជាតិឬខ្វិននៅពេលថ្មីៗនេះ ឈឺក តឹងច្រមុះឬហៀរសំបោរ ចង្អោរឬក្អួត និងរាករូះជាដើម។

បានកែសម្រួល: ថ្ងៃទី 7 ខែមករា ឆ្នាំ 2022

តើអ្វីទៅជាវ៉ាក់សាំង MODERNA COVID-19?

វ៉ាក់សាំង Moderna COVID-19 គឺជាវ៉ាក់សាំងដែលមិនទាន់មានការអនុម័ត តែវាអាចបង្ការជម្ងឺ COVID-19 បាន។

រដ្ឋបាលចំណីអាហារនិងឱសថសហរដ្ឋអាមេរិក(FDA)បានអនុម័តឲ្យប្រើប្រាស់ជាបន្ទាន់នៃវ៉ាក់សាំង Moderna COVID-19 ដើម្បីបង្ការជម្ងឺ COVID-19 ចំពោះមនុស្សដែលមានអាយុចាប់ពី 18ឆ្នាំឡើងទៅ ក្រោមការអនុញ្ញាតឲ្យប្រើប្រាស់ជាបន្ទាន់(EUA) ។

សម្រាប់ព័ត៌មានលម្អិតបន្ថែមស្តីពី EUA សូមអានផ្នែក "**តើអ្វីទៅជាការអនុញ្ញាតឲ្យប្រើប្រាស់ជាបន្ទាន់(EUA)?** " ដែលនៅចុងបញ្ចប់នៃបញ្ហិហេតុការណ៍នេះ។

.តើអ្វីខ្លះដែលអ្នកគួរលើកយកមកនិយាយជាមួយអ្នកផ្តល់ការចាក់វ៉ាក់សាំងបង្ការរោគ មុនពេលដែលអ្នកទទួលវ៉ាក់សាំង MODERNA COVID-19 VACCINE នេះ?

សូមប្រាប់អ្នកផ្តល់ការចាក់វ៉ាក់សាំងបង្ការរោគអំពីរាល់ស្ថានភាពសុខភាពរបស់អ្នក រួមទាំងរោគសញ្ញាទាំងឡាយប្រសិនបើអ្នកមាន:

- ប្រតិកម្មទាស់ណាមួយ
- ការរលាកសាច់ដុំបេះដូង ឬរោគរលាកស្រោមបេះដូង
- ក្រុនក្តៅ
- វិបត្តិឈាមកក ឬកំពុងប្រើប្រាស់ថ្នាំឈាមកក
- ការបាត់បង់ភាពស៊ាំទៅនឹងជម្ងឺ ឬកំពុងប្រើប្រាស់ថ្នាំដែលប៉ះពាល់ដល់ប្រព័ន្ធភាពស៊ាំរបស់អ្នក
- ផ្ទៃពោះ ឬគ្រោងនឹងមានផ្ទៃពោះ
- ការបំបៅកូនដោយទឹកដោះម្តាយ
- ទទួលបានវ៉ាក់សាំង COVID-19 ដទៃទៀត
- ធ្លាប់ដួលសន្លប់នៅពេលចាក់ថ្នាំ

តើអ្នកណាខ្លះដែលគួរទទួលបានវ៉ាក់សាំង MODERNA COVID-19 នេះ?
រដ្ឋបាលចំណីអាហារនិងឱសថសហរដ្ឋអាមេរិក(FDA)បានអនុម័តឲ្យប្រើប្រាស់ជាបន្ទាន់នៃវ៉ាក់សាំង Moderna COVID-19 ចំពោះមនុស្សដែលមានអាយុចាប់ពី 18ឆ្នាំឡើងទៅ។

តើអ្នកណាខ្លះដែល<u>មិនគួរ</u>ទទួលបានវ៉ាក់សាំង MODERNA COVID-19 នេះ?
អ្នកមិនគួរទទួលបានវ៉ាក់សាំង Moderna COVID-19 នេះទេ ប្រសិនបើអ្នក:

- មានប្រតិកម្មទាស់ធ្ងន់ធ្ងរបន្ទាប់ពីបានចាក់វ៉ាក់សាំងលើកទីមួយមក
- មានប្រតិកម្មទាស់ធ្ងន់ធ្ងរទៅនឹងធាតុផ្សំណាមួយនៃវ៉ាក់សាំងនេះ

តើអ្វីខ្លះជាធាតុផ្សំនៃវ៉ាក់សាំង MODERNA COVID-19 នេះ?
វ៉ាក់សាំង **Moderna** COVID-19 មានធាតុផ្សំដូចតទៅនេះ: messenger ribonucleic acid (mRNA), lipids (SM-102, polyethylene glycol [PEG] 2000 dimyristoyl glycerol [DMG], cholesterol, and 1,2-distearoyl-sn-glycero-3-phosphocholine [DSPC]), tromethamine, tromethamine hydrochloride, acetic acid, sodium acetate, និង sucrose។

តើវ៉ាក់សាំង MODERNA COVID-19 នេះនឹងត្រូវបានផ្តល់ជូនយ៉ាងដូចម្តេច?
គេនឹងចាក់វ៉ាក់សាំង Moderna COVID-19 ទៅក្នុងសាច់ដុំរបស់អ្នក។

<u>ស៊េរីលើកទីមួយ</u>៖ វ៉ាក់សាំង Moderna COVID-19 ត្រូវបានគេប្រើប្រាស់ជាស៊េរី 2 ដូសបន្តបន្ទាប់គ្នាក្នុងរយៈពេលមួយខែដាច់ដោយឡែកពីគ្នា។ ដូសជាស៊េរីលើកទីបីអាចត្រូវបានគេប្រើប្រាស់យ៉ាងហោចណាស់ចំនួនមួយខែបន្ទាប់ពីការចាក់លើកទីពីរដល់បុគ្គលដែលត្រូវបានកំណត់ថាមានប្រភេទមួយចំនួននៃការបាត់បង់ភាពស៊ាំទៅនឹងជម្ងឺ។

ចាក់ថ្នាំបង្ការរោគបន្ថែម៖

- ចាក់ថ្នាំបង្ការរោគបន្ថែមនៃវ៉ាក់សាំង Moderna COVID-19 តែមួយដងអាចត្រូវបានគេប្រើប្រាស់យ៉ាងហោចណាស់រយៈពេល 5 ខែ បន្ទាប់ពីបានបញ្ចប់សេរីលើកទីមួយ ។

- ចាក់ថ្នាំបង្ការរោគបន្ថែមតែមួយដងអាចត្រូវបានគេប្រើប្រាស់ចំពោះបុគ្គលដែលមានអាយុចាប់ពី 18ឆ្នាំឡើងទៅ ដែលបានចាក់វ៉ាក់សាំងលើកទីមួយជាមួយនឹងវ៉ាក់សាំង COVID-19 ដែលទទួលបានការអនុញ្ញាតផ្សេងគ្នា។
  សូមពិនិត្យជាមួយនឹងអ្នកផ្តល់សេវាសុខភាពរបស់អ្នកទាក់ទងទៅនឹងពេលវេលានៃការចាក់ថ្នាំបង្ការរោគបន្ថែមនេះ។

តើវ៉ាក់សាំង MODERNA COVID-19 នេះ ធ្លាប់បានគេប្រើប្រាស់ពីមុនមកដែរឬទេ?
វ៉ាក់សាំង Moderna COVID-19 នេះគឺជាវ៉ាក់សាំងដែលមិនទាន់អនុម័តនៅឡើយនោះទេ។
នៅក្នុងការសាកល្បងវេជ្ជសាស្ត្រ មានមនុស្សប្រមាណជា 15,400 នាក់ ដែលមានអាយុចាប់ពី18 ឆ្នាំឡើងទៅ បានទទួលយ៉ាងហោចណាស់ ចំនួនមួយកម្រិតប្រើប្រាស់នៃវ៉ាក់សាំង Moderna COVID-19 នេះ។
មនុស្សរាប់លាននាក់បានទទួលវ៉ាក់សាំងនេះក្រោម EUA ចាប់តាំងពីថ្ងៃទី 11 ខែធ្នូ ឆ្នាំ 2020 ។

តើវ៉ាក់សាំង MODERNA COVID-19 នេះ មានអត្ថប្រយោជន៍អ្វីខ្លះ?

នៅក្នុងការសាកល្បងវេជ្ជសាស្ត្រដែលកំពុងតែដំណើរការ វ៉ាក់សាំង Moderna COVID-19 នេះបានបង្ហាញនូវការបង្ការ COVID-19 បន្ទាប់ពីបានប្រើប្រាស់វាពីរកម្រិតក្នុងរយៈពេលមួយខែដោយឡែកពីគ្នា។
បច្ចុប្បន្ននេះ គេមិនទាន់បានដឹងពីរយៈពេលនៃការការពាររបស់វាប្រឆាំងនឹង COVID-19នេះនៅឡើយនោះទេ។.

តើវ៉ាក់សាំង MODERNA COVID-19 នេះ មានហានិភ័យអ្វីខ្លះ?

វាមានឱកាសតិចតួចដែលវ៉ាក់សាំង MODERNA COVID-19 នេះអាចបង្ករឲ្យមានប្រតិកម្មទាស់ធ្ងន់ធ្ងរ។
ប្រតិកម្មទាស់ធ្ងន់ធ្ងរ ជាធម្មតាគួរតែកើមមានឡើងក្នុងរយៈពេលពីរបីនាទីទៅមួយម៉ោង
បន្ទាប់ពីទទួលបានកម្រិតប្រើប្រាស់នៃវ៉ាក់សាំង MODERNA COVID-19នេះ។ ដោយមូលហេតុនេះហើយ
អ្នកផ្តល់សេវាចាក់វ៉ាក់សាំងរបស់អ្នកអាចស្នើសុំអ្នកឲ្យសំរាកនៅទីកន្លែងដែលអ្នកចាប់វ៉ាក់សាំងដើម្បីតាមដានក្រោយពីការចាក់វ៉ាក់សាំង។ រោគសញ្ញានៃការប្រតិកម្មទាស់ធ្ងន់ធ្ងរអាចរួមមាន:

- ពិបាកដកដង្ហើម
- ហើមមុខនិងការបស់អ្នក
- បេះដូងលោតញាប់
- ឡើងកន្ទួលជុំវិញដងខ្លួន
- វិលមុខនិងចុះខ្សោយ

ការលាកសាច់ដុំបេះដូងឬរោគរលាកស្រោមបេះដូងបានកើតមានឡើងទៅលើមនុស្សមួយចំនួនដែលបានចាក់វ៉ាក់សាំង Moderna COVID-19 នេះ។ ករណីជាច្រើននៃអ្នកទាំងនោះ
រោគសញ្ញាបានលេចឡើងក្នុងកំឡុងពេលពីបីថ្ងៃបន្ទាប់ពីបានការចាក់វ៉ាក់សាំង Moderna COVID-19 លើកទីពីរ។
ឱកាសនៃការកើតមានឡើងនូវរោគសញ្ញានេះមានតិចតួចជាទីបំផុត។
អ្នកគួរតែស្វែងរកការជួយសង្គ្រោះជាបន្ទាន់ភ្លាមៗ
ប្រសិនបើអ្នកមានរោគសញ្ញាដូចខាងក្រោមនេះបន្ទាប់ពីបានចាក់វ៉ាក់សាំង Moderna នេះ ៖

- ឈឺទ្រូង
- ពិបាកដកដង្ហើម
- មានអារម្មណ៍ថាបេះដូងលោតញាប់ ញ័រទ្រូងនិងចង្វាក់បេះដូងលោតខ្លាំងនិងញាប់ជាងធម្មតា។

ឥទ្ធិពលបន្ទាប់បន្សំដែលបានគេរាយការណ៍មកជាមួយនឹងវ៉ាក់សាំង Moderna COVID-19 នេះរួមមាន:

- ប្រតិកម្មទាស់នៅត្រង់កន្លែងដែលចាក់ : ឈឺត្រង់កន្លែងចាក ឡើងហើមទន់និងឈឺក្រពេញទឹករងៃនៅដៃដែលចាក់ ហើម(ឡើងរឹង)និងឡើងពណ៌ក្រហម
- ឥទ្ធិពលបន្ទាប់បន្សំទូទៅ: អស់កម្លាំង ឈឺក្បាល ឈឺសាច់ដុំ ឈឺសន្លាក់ ក្រុនញ័រក់ ចង់ក្អួត ក្អួត ក្រុននិងកន្ទួលស្បែក។

ឥទ្ធិពលបន្ទាប់បន្សំដែលបានរាយការណ៍ឲ្យដឹងក្រោយពីការអនុញ្ញាតឲ្យប្រើប្រាស់នូវវ៉ាក់សាំង Moderna COVID-19 នេះរួមមាន៖

- ប្រតិម្មទាស់ធ្ងន់ធ្ងរ
- រលាកសាច់ដុំបេះដូង
- រលាកស្រោមបេះដូង
- ដួលសន្លប់ដោយសារការចាក់វ៉ាក់សាំង

រោគសញ្ញាទាំងអស់នេះអាចមិនមែនសុទ្ធតែជាឥទ្ធិពលបន្ទាប់បន្សំនៃវ៉ាក់សាំង Moderna COVID-19 នេះ នោះទេ។ ឥទ្ធិពលបន្ទាប់បន្សំដែលមិនបានរំពឹងទុកហើយធ្ងន់ធ្ងរអាចនឹងកើតមានឡើង។ វ៉ាក់សាំង Moderna COVID-19នេះ កំពុងស្ថិតក្នុងការសិក្សាស្រាវជ្រាវនៅក្នុងការសាកល្បងវេជ្ជសាស្ត្រនៅឡើយទេ។

តើខ្ញុំគួរធ្វើអ្វីខ្លះអំពីឥទ្ធិពលបន្ទាប់បន្សំនេះ?

ប្រសិនបើអ្នកជួបប្រទះនឹងប្រតិកម្មទាស់ធ្ងន់ធ្ងរ សូមទូរស័ព្ទទៅកាន់លេខ 9-1-1
ឬទៅកាន់មន្ទីរពេទ្យដែលនៅជិតអ្នកបំផុត។

សូមទូរស័ព្ទទៅកាន់អ្នកផ្តល់ការចាក់វ៉ាក់សាំងបង្ការរោគ មន្ត្រីសុខាភិបាលរបស់អ្នក
ប្រសិនបើអ្នកមានឥទ្ធិពលបន្ទាប់បន្សំដែលរំខានអ្នកឬដែលមិនបាត់នោះ។

សូមរាយការណ៍ឥទ្ធិពលបន្ទាប់បន្សំនៃវ៉ាក់សាំងទៅកាន់ FDA/CDC
តាមរយៈប្រព័ន្ធរាយការណ៍ព្រឹត្តិការណ៍ធ្ងន់ធ្ងរនៃវ៉ាក់សាំង(VAERS)។ លេខទូរស័ព្ទដែលមិនគិតថ្លៃរបស់ VAERS គឺ 1-800-822-7967 ឬសូមរាយការណ៍តាមគេហទំព័រ https://vaers.hhs.gov/reportevent.html ។
សូមដាក់បញ្ចូលពាក្យ “Moderna COVID-19 Vaccine EUA” នៅក្នុងជួរទីមួយប្រអប់លេខ18
នៃទម្រង់បែបបទរាយការណ៍។

ជាងនេះទៅទៀត
អ្នកអាចរាយការណ៍អំពីឥទ្ធិពលបន្ទាប់បសន្សំនេះទៅក្រុមហ៊ុនបច្ចេកវិទ្យាខាងជីវសាស្ត្រសហរដ្ឋអាមេរិក(Moderna TX, Inc)តាមលេខ1-866-MODERNA (1-866-663-3762) ។

គេក៍អាចផ្តល់ជម្រើសអ្នកក្នុងការចុះឈ្មោះជាមួយនឹងវ៊ីសេហ្វ៍(**v-safe**)ផងដែរ។ **V-safe**
គឺជាឧបករណ៍ថ្មីមួយមាននៅលើទីរស័ព្ទដៃទំនើបដែលប្រើប្រាស់ដោយមិនគិតថ្លៃ
ដោយប្រើប្រាស់សារជាអត្ថបទនិងការស្ទង់មតិតាមគេហទំព័រដើម្បីចុះបញ្ជីអ្នកដែលបានចាក់វ៉ាក់សុាំងក្នុងការឃើញ
ឥទ្ធិពលបន្ទាប់បសន្សំជាសក្តានុពលបន្ទាប់ពីការចាក់វ៉ាក់សុាំង COVID-19 នេះ។ **V-safe**
សួរសំណួរទាំងឡាយដែលជួយ CDCត្រួតពិនិត្យសុវត្ថិភាពនៃវ៉ាក់សុាំង COVID-19 ។ **V-safe**
ក៏ផ្តល់នូវការរំលឹកការចាក់កម្រិតទីពីផងដែរ ប្រសិនបើចាំបាច់
និងការតាមដានត្រួតពិនិត្យដោយផ្ទាល់តាមទូរស័ព្ទជាមួយ CDC
ប្រសិនបើអ្នកចូលរួមរាយការណ៍មកថាមានផលប៉ះពាល់សុខភាពគួរឲ្យកត់សម្គាល់បន្ទាប់ពីបានចាក់វ៉ាក់សុាំង COVID-19 នេះ។ សម្រាប់ព័ត៌មានលម្អិតស្តីអំពីរបៀបចុះឈ្មោះ សូមមើលគេហទំព័រ www.cdc.gov/vsafe ។

តើវានឹងមានអ្វីកើតឡើងប្រសិនបើខ្ញុំមិនទទួលយកវ៉ាក់សាំង MODERNA COVID-19 **នេះ?**

វាគឺជាជម្រើសរបស់អ្នកក្នុងការទទួលយកឬមិនទទួលយកវ៉ាក់សាំង Moderna COVID-19 នេះ។
ប្រសិនបើអ្នកសម្រេចចិត្តមិនទទួលយកវា
វានឹងមិនមានការផ្លាស់ប្តូរស្តង់ដារការព្យាបាលសុខភាពរបស់អ្នកនោះទេ។

តើមានជម្រើសដទៃណាផ្សេងទៀតដែរឬទេ សម្រាប់បង្ការជម្ងឺ COVID-19នេះ ក្រៅពីវ៉ាក់សាំង MODERNA COVID-19 នោះ?

ជម្រើសមួយទៀតសម្រាប់បង្ការជម្ងឺ COVID-19 គឺវ៉ាក់សាំង Comirnaty ដែលជាវ៉ាក់សាំង COVID-19
ទទួលបានការអនុម័តដោយ FDA ។ វ៉ាក់សាំងដទៃៗផ្សេងទៀតដើម្បីបង្ការជម្ងឺ COVID-19
អាចរកបាននៅក្រោមការអនុញ្ញាតឲ្យប្រើប្រាស់ជាបន្ទាន់។

តើខ្ញុំអាចទទួលវ៉ាក់សាំង MODERNA COVID-19 នេះ ជាមួយនឹងវ៉ាក់សាំងជនិទែផ្សេងទៀតដែរឬទេ?

វាមិនទាន់មានទិន្នន័យដែលត្រូវបានដាក់ជូន FDA ស្តីពីការប្រើប្រាស់វ៉ាក់សាំង Moderna COVID-19 ក្នុងពេលតែមួយជាមួយវ៉ាក់សាំងផ្សេងទៀតនោះទេ។ ប្រសិនបើអ្នកកំពុងពិចារណាទទួលវ៉ាក់សាំង Moderna COVID-19 ជាមួយវ៉ាក់សាំងផ្សេងទៀត សូមពិភាក្សាអំពីជម្រើសរបស់អ្នកជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

តើនឹងមានអ្វីកើតមានឡើងប្រសិនបើខ្ញុំមានការជាក់បង់ភាពស៊ាំទៅនឹងជម្ងឺ?

ប្រសិនបើអ្នកមានការជាក់បង់ភាពស៊ាំទៅនឹងជម្ងឺ អ្នកអាចទទួលបានវ៉ាក់សាំងកម្រិតប្រើលើកទីបី។ កម្រិតប្រើលើកទី 3 ប្រហែលជានៅតែមិនផ្តល់ភាពស៊ាំពេញលេញទៅនឹងជម្ងឺ COVID-19 ចំពោះអ្នកដែលមានការជាក់បង់ភាពស៊ាំទៅនឹងជម្ងឺនោះទេ
ហើយអ្នកគួរតែបន្តរក្សាការប្រុងប្រយ័ត្នរាងកាយដើម្បីជួយការពារ ជម្ងឺCOVID-19នេះ។ លើសពីនេះ
អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកគួរតែត្រូវបានចាក់វ៉ាក់សាំងតាមការសមស្របផងដែរ។

តើនឹងមានអ្វីកើតមានឡើង ប្រសិនបើខ្ញុំកំពុងមានផ្ទៃពោះឬកំពុងបំបៅកូនដោយទឹកដោះនោះ?

ប្រសិនបើអ្នកកំពុងមានផ្ទៃពោះឬកំពុងបំបៅកូនដោយទឹកដោះនោះ
សូមពិភាក្សាជម្រើសរបស់អ្នកជាមួយនឹងអ្នកផ្តល់សេវាសុខភាពរបស់អ្នក។

តើវ៉ាក់សាំងMODERNA COVID-19នេះនឹងធ្វើឲ្យខ្ញុំកើតជម្ងឺCOVID-19ដែរឬទេ?

ទេ វ៉ាក់សាំង Moderna COVID-19នេះមិនមានផ្ទុកវីរុសSARS-CoV-2 និងមិនអាចធ្វើឲ្យអ្នកមានជម្ងឺCOVID-19នោះទេ។

សូមរក្សាប័ណ្ណចាក់វ៉ាក់សាំងបង្ការរោគរបស់អ្នក

នៅពេលដែលអ្នកទទួលបានការចាក់ថ្នាំលើកទីមួយ
គេនឹងផ្តល់ប័ណ្ណចាក់ថ្នាំបង្ការរោគមួយសន្លឹកដល់អ្នកដើម្បីឲ្យអ្នកបង្ហាញវានៅពេលដែលអ្នកត្រឡប់មកចាក់វ៉ាក់សាំង Moderna COVID-19 នេះជាលើកទីពីរ។ ដូច្នេះសូមកុំភ្លេចយកប័ណ្ណរបស់អ្នកនៅពេលដែលអ្នកត្រឡប់មកវិញ។

ព័ត៌មានបន្ថែម

ប្រសិនបើអ្នកមានសំណួរ សូមរកមើលនៅតាមគេហទំព័រ ឬទូរស័ព្ទមកលេខដែលផ្តល់ជូនដូចខាងក្រោមនេះ។

ដើម្បីទទួលបាននូវបញ្ហិហេតុការណ៍ថ្មីៗបំផុត សូមធ្វើការស្កេនកូដ QR ដែលបានផ្តល់ដូចខាងក្រោមនេះ។

គេហទំព័រវ៉ាក់សាំងModerna COVID-19	**លេខទូរស័ព្ទ**
www.modernatx.com/covid19vaccine-eua	1-866-MODERNA (1-866-663-3762)

តើខ្ញុំអាចបានដំណឹងជាបន្ថែមទៀតយ៉ាងដូចម្តេច?

- សូមសួរទៅអ្នកផ្តល់ការចាក់វ៉ាក់សាំងបង្ការរោគ។
- សូមមើលCDCតាមរយៈគេហទំព័រ https://www.cdc.gov/coronavirus/2019-ncov/index.html.
- សូមមើលFDA តាមរយៈគេហទំព័រ https://www.fda.gov/emergency-preparedness-and-response/mcm-legal-regulatory-and-policy-framework/emergency-use-authorization.
- សូមទាក់ទងជាមួយនឹងផ្នែកសុខាភិបាលសាធារណៈនៅក្នុងតំបន់ឬរដ្ឋរបស់អ្នក។

បានកែសម្រួល: ថ្ងៃទី 7 ខែមករា ឆ្នាំ 2022

តើព័ត៌មានស្តីពីការចាក់ថ្នាំបង្ការរោគរបស់ខ្ញុំនឹងត្រូវបានកត់ត្រាទុកនៅទីណា?
អ្នកផ្តល់ការចាក់វ៉ាក់សាំងបង្ការរោគអាចបញ្ចូលព័ត៌មានស្តីពីការចាក់វ៉ាក់សាំងបង្ការរោគរបស់អ្នកនៅក្នុងប្រព័ន្ធព័ត៌មានភាពស៊ាំនៃដែនសមត្ថកិច្ចតំបន់ឬរដ្ឋរបស់អ្នក(IIS)ឬប្រព័ន្ធដទៃផ្សេងទៀតដែលបានចាត់តាំងឡើង។
នេះនឹងធ្វើឲ្យប្រាដកថាអ្នកទទួលបានវ៉ាក់សាំងដដែលនៅពេលដែលអ្នកត្រឡប់មកចាក់កម្រិតប្រើប្រាស់លើកទីពីរ។
សម្រាប់ព័ត៌មានលម្អិតបន្ថែមស្តីអំពី IIS សូមមើលគេហទំព័រ: https://www.cdc.gov/vaccines/programs/iis/about.html

តើខ្ញុំអាចនឹងចេញថ្លៃរដ្ឋបាលដើម្បីទទួលបានវ៉ាក់សាំងកូវីដ19 នេះដែរឬទេ?
ទេ នៅពេលនេះ អ្នកផ្តល់វ៉ាក់សាំងមិនអាចគិតថ្លៃពីអ្នកចំពោះកម្រិតប្រើប្រាស់វ៉ាក់សាំងនោះទេ
ហើយអ្នកមិនត្រូវបានយកប្រាក់ពីហោប៉ៅអ្នកដើម្បីទូទាត់ថ្លៃរដ្ឋបាលឬថ្លៃចំណាយដទៃទៀតនោះទេ
នៅពេលដែលអ្នកគ្រាន់តែទទួលវ៉ាក់សាំងកូវីដ19តែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ
អ្នកផ្តល់វ៉ាក់សាំងអាចនឹងស្វែងរកសំណងសមស្របពីកម្មវិធីឬគម្រោងដែលចេញថ្លៃរដ្ឋបាលវ៉ាក់សាំងកូវីដ19សម្រាប់អ្នកទទួលវ៉ាក់សាំង(ក្រុមហ៊ុនធានារ៉ាប់រងឯកជន ការធានារ៉ាប់រងសុខភាពរបស់រដ្ឋសហព័ន្ធ កម្មវិធីធានាសុខភាពសាធារណៈ កម្មវិធីទាមទារសំណងHRSA COVID-19ដែលមិនត្រូវបានធានាសម្រាប់អ្នកទទួលដែលមិនមានការធានារ៉ាប់រង)។

តើខ្ញុំអាចរាយការណ៍អំពីករណីសង្ស័យបោកបន្លំទៅទីណាដែរ?
រាល់បុគ្គលនីមួយៗដែលបានដឹងអំពីការរំលោភបំពានជាសកម្មភាពណាមួយទៅលើគម្រោងកម្មវិធីចាក់វ៉ាក់សាំងកូវីដ19របស់ស៊ីឌីស៊ី(CDC)ត្រូវបានលើកទឹកចិត្តដើម្បីរាយការណ៍ករណីទាំងនោះទៅកាន់ការិយាល័យអគ្គអធិការកិច្ចនៃក្រសួងសុខាភិបាលនិងសេវាមនុស្សសហរដ្ឋអាមេរិកតាមរយៈលេខ1-800-HHS-TIPS ឬ https://TIPS.HHS.GOV ។

តើអ្វីទៅជាប្រតិវិធានការនៅក្នុងកម្មវិធីសំណងរបួសនោះ?
ប្រតិវិធានការនៅក្នុងកម្មវិធីសំណងរបួស(CICP)គឺជាកម្មវិធីសហព័ន្ធមួយដែលអាចជួយចេញថ្លៃព្យាបាលជម្ងឺនិងចំណាយជាក់ស្តែងផ្សេងៗទៀតនៃមនុស្សមួយចំនួនដែលបានទទួលរងគ្រោះធ្ងន់ធ្ងរដោយឱសថឬវ៉ាក់សាំងបង្ការរោគមួយចំនួន
រួមទាំងវ៉ាក់សាំងនេះផងដែរ។ ជាទូទៅ ការទាមទារសំណងត្រូវដាក់ជូនឲ្យ CICP
ពិនិត្យនិងសម្រេចក្នុងរយៈពេលមួយឆ្នាំចាប់ពីកាលបរិច្ឆេទនៃការទទួលវ៉ាក់សាំងនេះ។ ដើម្បីបានដឹងបន្ថែមអំពីកម្មវិធីនេះ
សូមមើលគេហទំព័រwww.hrsa.gov/cicp/ ឬទូរស័ព្ទទៅកាន់លេខ 1-855-266-2427 ។

តើអ្វីទៅគឺជាការអនុញ្ញាតឲ្យប្រើប្រាស់ជាបន្ទាន់(EUA)នោះ?

រដ្ឋបាលចំណីអាហារនិងឱសថសហរដ្ឋអាមេរិក(The United States FDA)បានអនុញ្ញាតឲ្យប្រើប្រាស់វ៉ាក់សាំង Moderna COVID-19នេះ នៅក្រោមយន្តការអាចយកមកប្រើប្រាស់ជាបន្ទាន់ដែលគេហៅថា EUA ។ EUA
នេះត្រូវបានគាំទ្រដោយរដ្ឋមន្ត្រីសុខាភិបាលនិងសេចក្តីប្រកាសសេវាកម្មមនុស្ស(HHS)ដែលថាកាល:ទេស:កើតមានឡើងដើម្បីផ្តល់ហេតុផលត្រឹមត្រូវនូវការប្រើប្រាស់ជាបន្ទាន់នៃឱសថនិងផលិតផលជីវសាស្ត្រក្នុងកំឡុងពេលនៃការរាលដាលទៅគ្រប់ទីកន្លែងនៃជម្ងឺ COVID-19 ។

វ៉ាក់សាំង Moderna COVID-19នេះមិនបានធ្វើការត្រួតពិនិត្យឡើងវិញដូចគ្នាទៅនឹងប្រភេទផលិតផលដែលបានទទួលការត្រួតពិនិត្យឬអនុម័តដោយ FDAនោះទេ។ FDAអាចផ្តល់ EUA នៅពេលដែលបានបំពេញនូវលក្ខខណ្ឌមួយចំនួន ដែលរាប់បញ្ចូលថា
វាគ្មានជម្រើសការអនុម័ត និងមានមិនគ្រប់គ្រាន់ ។ ជាងនេះទៅទៀត ការសម្រេចចិត្តរបស់ FDA
គឺផ្អែកទៅលើភស្តុតាងវិទ្យាសាស្ត្រទាំងស្រុងដែលមាន ដោយបានបង្ហាញថា
ផលិតផលនេះអាចមានប្រសិទ្ធិភាពក្នុងការបង្ការជម្ងឺ COVID-19 ក្នុងកំឡុងពេលនៃការរាលដាលទៅគ្រប់ទីកន្លែងនៃជម្ងឺ COVID-19 ហើយថា
អត្ថប្រយោជន៍ជាច្រើនដែលគេបានដឹងមានតម្លៃជាងហានិភ័យជាច្រើនដែលគេបានដឹងនៃផលិតផលនេះ។
លក្ខខណ្ឌទាំងអស់ត្រូវតែបានបំពេញដើម្បីអនុញ្ញាតឲ្យផលិតផលត្រូវបានគេយកមកប្រើប្រាស់ក្នុងការព្យាបាលអ្នកជម្ងឺក្នុងកំឡុងពេលនៃការរាលដាលទៅគ្រប់ទីកន្លែងនៃជម្ងឺ COVID-19 នេះ។

EUAសម្រាប់វ៉ាក់សាំង Moderna COVID-19នេះ ចូលជាធរមានសម្រាប់រយៈពេលនៃជម្ងឺ COVID-19 ដែលសេចក្តីប្រកាសរបស់ EUAបញ្ជាក់ថាផ្តល់ហេតុផលត្រឹមត្រូវនូវការប្រើប្រាស់ជាបន្ទាន់នៃផលិតផលទាំងនេះ
ប្រសិនបើវាមិនត្រូវបានគេបញ្ឈប់ឬលុបចោលវិញនោះទេ(បន្ទាប់ពីនោះមក
ផលិតផលអាចនឹងលែងត្រូវបានគេប្រើប្រាស់ទៀតហើយ)។
EUAសម្រាប់វ៉ាក់សាំង Moderna COVID-19នេះ ចូលជាធរមានសម្រាប់រយៈពេលនៃជម្ងឺ COVID-19 ដែលសេចក្តីប្រកាសរបស់ EUAបញ្ជាក់ថាផ្តល់ហេតុផលត្រឹមត្រូវនូវការប្រើប្រាស់ជាបន្ទាន់នៃផលិតផលទាំងនេះ
ប្រសិនបើវាមិនត្រូវបានគេបញ្ឈប់ឬលុបចោលវិញនោះទេ(បន្ទាប់ពីនោះមក
ផលិតផលអាចនឹងលែងត្រូវបានគេប្រើប្រាស់ទៀតហើយ)។

Moderna US, Inc.
Cambridge, MA
02139

©2021 ModernaTX, Inc. រក្សាសិទ្ធីគ្រប់យ៉ាង។
ប៉ាតង់: www.modernatx.com/patents
បានកែសម្រួល: ថ្ងៃទី 7 ខែមករា ឆ្នាំ2022